គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៧១ ចេញផ្សាយថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣
No. 71 Released on May 10, 2023

# អត្ថបទប្រចាំសប្ដាហ៍ | Weekly Article

## តើសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ជាអ្វី?

## What is Escrow Services?




https://img.staticmb.com/mbcontent//images/uploads/2022/12/escrow-account-helps-in-transparency.jpg

សេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) សំដៅដល់ប្រតិបត្តិការដែលក្នុងនោះ ម្ចាស់ទ្រព្យបានប្រគល់ទ្រព្យរបស់ខ្លួនឱ្យទៅធនាគារពាណិជ្ជ ដែលទទួលបានអាជ្ញាបណ្ណឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ធ្វើជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាទុក/រក្សាសុវត្ថិភាព(Escrow Services) ដើម្បីរក្សាសុវត្ថិភាព ឬរក្សាទុក តាមរយៈការបង្កើតគណនី Escrow ក្នុងគោលបំណងដើម្បីធ្វើការទូទាត់ ឬប្រគល់ទ្រព្យនោះទៅឱ្យបុគ្គលណាមួយ ក្នុងប្រតិបត្តិការធុរកិច្ច ឬក្នុងប្រតិបត្តិការអចលនទ្រព្យ ឬក្នុងប្រតិបត្តិការវិនិយោគនានា នៅពេលកំណត់ជាក់លាក់ណាមួយ តាមលក្ខខណ្ឌដែលបានព្រមព្រៀង។

ប្រតិបត្តិការសេវារក្សាទុក/រក្សាសុវត្ថិភាព (Escrow Services) ដែលមានអនុលោមភាពតាមច្បាប់ និងចុះបញ្ជីបរធនបាលកិច្ចត្រឹមត្រូវ ផ្ដល់នូវអត្ថប្រយោជន៍មួយចំនួនដែលរួមមាន÷ ១.អាចជួយការពារហានិភ័យ បង្កើតទំនុកចិត្ត និងបង្កើនសុវត្ថិភាពដល់ភាគីពាក់ព័ន្ធ និង២. មានអនុលោមភាព និងការគាំពារដោយច្បាប់ និងមាននិយ័តករធ្វើការតាមដាន និងត្រួតពិនិត្យទៅលើប្រតិបត្តិការនោះ។

យោងតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ធនាគារពាណិជ្ជដែលអាចធ្វើជាប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច ត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច។

Escrow services refers to transactions in which the owner of a property is entrusted to a commercial bank licensed or authorized by the Trust Regulator (**TR**), operates escrow services to maintain/secure escrow by creating an escrow account for the purpose of making payments or handing over assets to any person through business or term of real estate or other investment transactions at a specific time after any agreed terms.

The operation of escrow services that complies with the law and is properly registered provides a number of benefits, including: 1. help prevent risks, build trust and increase security to stakeholders and 2. carry out a proper and legal trust operation and have a regulator to monitor and control the operation of the escrow service.

According to the relevant laws and regulations in force, commercial banks that can act as a trust operator, provides escrow services in the trust sector must obtain a license/authorization from the Trust Regulator.

**អត្ថបទ÷ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References:**

- ច្បាប់ស្ដីពីបរធនបាលកិច្ច (២០១៩) និងបទប្បញ្ញត្តិពាក់ព័ន្ធ
- https://www.investopedia.com/terms/e/escrow.asp
- https://www.thebalancemoney.com/what-is-escrow-315826

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.